**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០០៧ សហវ.ណ.ស.ល.២០២៤

# សារាចរណែនាំ
# ស្តីពី
# ការពង្រឹង ការកែលម្អ ការគ្រប់គ្រង សម្បទានគ្រប់គ្រងសេវាសាធារណៈ និង លើចំណតរថយន្តនៅតាមច្រកទ្វារព្រំដែន

កន្លងមក ក្នុងការពង្រឹងការគ្រប់គ្រងសម្បទានគ្រប់គ្រងសេវាសាធារណៈ ដែលហៅថា “ការធ្វើអាជីវកម្មភាស៊ីគ្រប់ប្រភេទ” មានជាអាទិ៍÷ ផ្សារ, កំពង់ចម្លង, ចំណតរថយន្ត, ចំណតជលយាន, មណ្ឌលបែងចែកផលនេសាទ (យៀត្រី), សត្តឃាតដ្ឋាន, ទីកន្លែងដាក់សំរាម, សេវាអនាម័យ និងបរិស្ថាន, ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្មទ្រព្យសម្បត្តិរបស់រដ្ឋ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដើម្បីពង្រឹងការគ្រប់គ្រង និងការអនុវត្តឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពលើការធ្វើអាជីវកម្មភាស៊ីគ្រប់ប្រភេទ ឱ្យស្របតាមលក្ខខណ្ឌ ដែលបានកំណត់ក្នុងកិច្ចសន្យា និងសៀវភៅបន្ទុក ព្រមទាំងបានដាក់ចេញការអនុវត្តការកែទម្រង់ តាមរយៈការធ្វើវិមជ្ឈការការគ្រប់គ្រងដោយផ្ទេរសិទ្ធិអំណាច និងការចាត់ចែងលើការគ្រប់គ្រងការធ្វើអាជីវកម្មភាស៊ីគ្រប់ប្រភេទ ឱ្យស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងស្មារតីបង្កើនប្រសិទ្ធភាពនៃការទទួលខុសត្រូវបន្ថែមទៀតលើការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ និងអាជីវករទាំងអស់នៅទូទាំងប្រទេស។

ជាក់ស្តែង តាមការអនុវត្តកន្លងមកនេះឃើញថា ការធ្វើអាជីវកម្មភាស៊ីគ្រប់ប្រភេទនៅតែបន្តកើតមានបញ្ហាជាច្រើនទៀត មានជាអាទិ៍÷

- ការរៀបចំកិច្ចសន្យា និងសៀវភៅបន្ទុក នៅមិនទាន់គ្រប់ជ្រុងជ្រោយស្របនឹងស្ថានភាពជាក់ស្តែង នៃភូមិសាស្ត្រ និង សេដ្ឋកិច្ចសង្គម
- ការផ្ទេរសិទ្ធិកិច្ចសន្យាដោយភាគីឯកជន មិនគោរពតាមនីតិវិធីដែលបានកំណត់
- បុគ្គលឯកជន ដែលធ្វើអាជីវកម្មភាស៊ីបានបំពានលក្ខខណ្ឌមានចែងក្នុងកិច្ចសន្យា និងសៀវភៅបន្ទុក មានជាអាទិ៍៖ ការប្រមូលភាស៊ីលើសតម្លៃដែលបានកំណត់, មិនប្រើប្រាស់ប័ណ្ណអាជីវកម្មភាស៊ី ដូចមានចែងក្នុងសៀវភៅបន្ទុក
- ការធ្វើអាជីវកម្មភាស៊ីចំណតយានយន្ត ពិសេសនៅតាមបណ្តាទីតាំងរមណីយដ្ឋាននានា និងចំណតរថយន្តនៅតាមច្រកទ្វារព្រំដែន បុគ្គលឯកជននៅតែបំពានលើលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍អនុញ្ញាត



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- យន្តការគ្រប់គ្រង តាមដាន និងប្រព័ន្ធនៃការត្រួតពិនិត្យដោយរដ្ឋបាលរាជធានី ខេត្ត លើការធ្វើអាជីវកម្មភាស៊ីរបស់បុគ្គលឯកជន នៅមានកម្រិត ដែលមិនទាន់អាចធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ និងធ្វើឱ្យប៉ះពាល់ដល់ការគ្រប់គ្រងចំណូល ការកៀរគរ និងការប្រមូលចំណូលមិនមែនសារពើពន្ធ។

បញ្ហាទាំងនេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សតិអារម្មណ៍របស់ភ្ញៀវទេសចរ, អាជីវករ, កសិករដែលនាំចេញផលិតផល, រាំងស្ទះដល់លំហូរទំនិញ និងកិច្ចសម្រួលពាណិជ្ជកម្ម, បង្កើនបន្ទុកចំណាយនៃការធ្វើធុរកិច្ច និងជាពិសេសប៉ះពាល់ដល់ការប្រមូលចំណូលរបស់អង្គភាពគយនិងរដ្ឋាករ ព្រមទាំងការត្រួតពិនិត្យលើការគ្រប់គ្រងទំនិញនាំចេញ-នាំចូល ព្រមទាំងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាល ។

ក្នុងគោលបំណងបន្តពង្រឹងការអនុវត្ត និងការគ្រប់គ្រងអាជីវកម្មភាស៊ីគ្រប់ប្រភេទ ប្រកបដោយភាពត្រឹមត្រូវ និងគុណភាព ក្នុងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋផង និងប្រសិទ្ធភាពនៃការប្រមូលចំណូលផង ព្រមទាំងផ្អែកតាមតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២៣ លើលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមដាក់ចេញបន្ថែមនូវវិធានការ និងសេចក្ដីណែនាំ ដូចខាងក្រោម÷

## ក.ការធ្វើអាជីវកម្មភាស៊ីគ្រប់ប្រភេទ

បុគ្គលឯកជន ដែលធ្វើអាជីវកម្មភាស៊ីគ្រប់ប្រភេទ ត្រូវបានហាមឃាត់ដាច់ខាត ក្នុងការអនុវត្តអាជីវកម្មភាស៊ីគ្រប់ប្រភេទរបស់ខ្លួន ដូចខាងក្រោម÷

១. ការប្រមូលភាស៊ីលើសពីដែនភូមិសាស្ត្រ ដែលបានកំណត់ក្នុងកិច្ចសន្យា និងសៀវភៅបន្ទុក។

២. ការបង្កើតក្រុមទារភាស៊ី ដែលផ្ទុយពីការអនុញ្ញាតរបស់រដ្ឋបាលរាជធានី ខេត្ត។

៣. ការដាក់រនាំងទារភាស៊ីតាមផ្លូវសាធារណៈ ផ្ទុយពីការកំណត់ក្នុងសៀវភៅបន្ទុក។

៤. ការបង្ខិតបង្ខំគ្រប់រូបភាពលើប្រជាជនទូទៅឱ្យបង់ថ្លៃភាស៊ី ដែលមិនបានប្រើប្រាស់សេវាអាជីវកម្មភាស៊ីនេះ។

## ខ.ការធ្វើអាជីវកម្មភាស៊ីលើចំណតយានយន្តទូទាំងប្រទេស និងនៅតាមច្រកទ្វារព្រំដែន

ត្រូវបានហាមឃាត់ដាច់ខាត ចំពោះការធ្វើអាជីវកម្មភាស៊ី លើចំណតយានយន្តទូទាំងប្រទេស និងនៅតាមច្រកទ្វារព្រំដែន នូវទង្វើ ដូចខាងក្រោម÷

១. ការដាក់រនាំងនៅតាមផ្លូវសាធារណៈ ឬនៅតាមច្រកទ្វារព្រំដែន ដើម្បីទារភាស៊ីលើយានយន្តដឹកអ្នកដំណើរ និងដឹកទំនិញឆ្លងកាត់។

២. ការស្ទាក់យានយន្តដឹកអ្នកដំណើរ និងដឹកទំនិញឆ្លងកាត់តាមផ្លូវ ដែលមិនមានតម្រូវការប្រើប្រាស់ចំណត ឱ្យបង់ថ្លៃអាជីវកម្មភាស៊ី។

៣. ការតាំងខ្លួន ឬបន្លំជាមន្ត្រីមានសមត្ថកិច្ច ដើម្បីបង្ខិតបង្ខំឱ្យអ្នកដឹកជញ្ជូនចូលចតក្នុងចំណតរបស់ខ្លួនស្ថិតនៅតាមច្រកទ្វារព្រំដែន ទោះបីមិនមានតម្រូវការប្រើប្រាស់ចំណតនេះ។

៤. ការបង្កើតអាជីវកម្មភាស៊ីចំណតយានយន្តនៅតាមច្រកទ្វារព្រំដែន ដែលបង្កឱ្យមានឧបសគ្គដល់ការបំពេញភារកិច្ចរបស់អង្គភាពគយ និងរដ្ឋាករ លើកិច្ចសម្រួលពាណិជ្ជកម្ម និងលំហូរទំនិញនាំចេញ-នាំចូល ព្រមទាំងការប្រមូលចំណូលចូលថវិការដ្ឋ។

**គ. យន្តការគ្រប់គ្រងការធ្វើអាជីវកម្មភាស៊ីគ្រប់ប្រភេទ**

ត្រូវពង្រឹងយន្តការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យ អាជីវកម្មភាស៊ីគ្រប់ប្រភេទ តាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម÷

១. ចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទាំងឡាយណា ដែលពុំទាន់បានបង្កើតគណៈកម្មការ/អនុគណៈកម្មការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យអាជីវកម្មភាស៊ីគ្រប់ប្រភេទ តាមការកំណត់របស់សារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្ម ទ្រព្យសម្បត្តិរបស់រដ្ឋ នៅឡើយទេនោះ ចាំបាច់ត្រូវបង្កើតនូវយន្តការនេះជាការប្រញាប់។

២. ក្នុងករណីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបង្កើតយន្តការគណៈកម្មការ/ អនុគណៈកម្មការនេះរួចហើយ តែពុំគោរពតាមការកំណត់ នៃសារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្ម ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរៀបចំបង្កើតយន្តការឡើងវិញ ដើម្បីធានាដល់ការងារគ្រប់គ្រង តាមដាន និងត្រួតពិនិត្យអាជីវកម្មភាស៊ី នៅតាមភូមិសាស្ត្រ និងសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយតម្លាភាព គណនេយ្យភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

៣. គណៈកម្មការ/អនុគណៈកម្មការ ត្រូវបំពេញការងារចុះត្រួតពិនិត្យជាប្រចាំ លើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកអាជីវកម្មភាស៊ីគ្រប់ប្រភេទរបស់ភាគីឯកជន ជាពិសេសក្នុងឱកាសពិធីបុណ្យទាន ដែលជាពេលវេលានៃការធ្វើដំណើរទេសចរ និងការជួបជុំរបស់ប្រជាពលរដ្ឋ។

៤. រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ឱ្យបានគ្រប់ជ្រុងជ្រោយ លើការរៀបចំកិច្ចសន្យា និងសៀវភៅបន្ទុក ឱ្យស្របតាមគោលការណ៍កំណត់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

៥. គណៈកម្មការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យ អាជីវកម្មភាស៊ីគ្រប់ប្រភេទរបស់ខេត្ត ត្រូវតាមដាន និងត្រួតពិនិត្យការអនុវត្តអាជីវកម្មចំណតយានយន្តនៅតាមច្រកទ្វារព្រំដែន ដោយគោរពតាមវិធានការដែលបានកំណត់នៅក្នុងចំណុច **ខ** ខាងលើនៃសារាចរណែនាំនេះ។

៦. គណៈកម្មការ/អនុគណៈកម្មការ ត្រូវមានរបបកិច្ចប្រជុំយ៉ាងតិចមួយដង ក្នុងមួយត្រីមាស ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងបញ្ហា ដែលអាចកើតមានឡើង ដើម្បីកែលម្អ និងចាត់វិធានការដោះស្រាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ។

៧. រដ្ឋបាលរាជធានី ខេត្ត ត្រូវពង្រឹងការអនុវត្តយន្តការនៃការធ្វើរបាយការណ៍ឡើងវិញ ឱ្យបានម៉ត់ចត់ទៀងទាត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ស្របទៅតាមការកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដូចខាងក្រោម÷

- រដ្ឋបាលរាជធានី ខេត្ត ត្រូវបូកសរុបរបាយការណ៍ស្តីពីការអនុវត្តការធ្វើអាជីវកម្មភាស៊ី និងការអនុវត្តចំណូលមិនមែនសារពើពន្ធ ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានទៀងទាត់ជារៀងរាល់ខែ ដោយមានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយនឹង ទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្ត ជាសេនាធិការ ក្នុងការងារគ្រប់គ្រង តាមដាន និងការប្រមូលចំណូលនេះ។
- បន្ទាប់មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត ត្រូវបូកសរុបរបាយការណ៍ឱ្យបានទៀងទាត់ នៅរៀងរាល់ខែយ៉ាងយូរត្រឹមថ្ងៃទី០៥ នៃខែបន្ទាប់ជាកំហិតរួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ) ដើម្បីអនុវត្តតាមមុខការរបស់ខ្លួន។

៨. ប័ណ្ណអាជីវកម្មភាស៊ីគ្រប់ប្រភេទ ត្រូវចេញដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ទើបទទួលស្គាល់ជាផ្លូវការ។ ក្នុងករណី ភាគីឯកជន បានបង្កើតប័ណ្ណអាជីវកម្មភាស៊ីដោយខ្លួនឯងផ្ទាល់ ត្រូវចាត់ទុកថាជាការបំពានលើកិច្ចសន្យា និងសៀវភៅបន្ទុក។ ប័ណ្ណអាជីវកម្មភាស៊ី ត្រូវមានបញ្ជាក់ឱ្យបានច្បាស់លាស់ ជាអាទិ៍÷ មុខសញ្ញាអាជីវកម្មភាស៊ី, តម្លៃ, កាលបរិច្ឆេទ, សុពលភាព។

៩. រដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់វិធានការពង្រឹងការត្រួតពិនិត្យសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ ការរក្សាអនាម័យ បរិស្ថាន នៅលើទីតាំងដែលបានផ្តល់សិទ្ធិធ្វើអាជីវកម្មភាស៊ី ដើម្បីធានាសណ្តាប់ធ្នាប់សន្តិសុខជូនប្រជាពលរដ្ឋ អ្នកធ្វើដំណើរ ភ្ញៀវទេសចរ និងអាជីវករ។

១០. រដ្ឋបាលរាជធានី ខេត្ត និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចាត់វិធានការលើបុគ្គល ដែលប្រព្រឹត្តល្មើសនឹងកិច្ចសន្យា សៀវភៅបន្ទុក ឬល្មើសនឹងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយអនុវត្តទៅតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា សៀវភៅបន្ទុក និងការទទួលខុសត្រូវចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៩០ ៩១, ៩២, ៩៤, ៩៥, ៩៦ និងមាត្រា ៩៧ ក្នុងជំពូកទី១០ ស្តីពីទោសប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២២ ដោយមិនទាន់រាប់បញ្ចូលទោសព្រហ្មទណ្ឌ ទៅតាមកម្រិតនៃទោសទណ្ឌ។

១១. រដ្ឋបាលរាជធានី ខេត្ត ត្រូវពិនិត្យកែតម្រូវ ឬបំពេញបន្ថែមឡើងវិញ ចំពោះកិច្ចសន្យា និងសៀវភៅបន្ទុកទាំងឡាយណា ដែលមិនអនុលោមតាមខ្លឹមសារនៃសារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្ម ទ្រព្យសម្បត្តិរបស់រដ្ឋ និងសារាចរណែនាំនេះ ព្រមទាំងត្រូវកំណត់នូវលក្ខខណ្ឌនៃការពិន័យ និងទោសព្រហ្មទណ្ឌ ស្របតាមជំពូកទី ១០ ស្តីពីទោសប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលឯកជនពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ព្រហ ៤ កើត ខែអាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ